ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខៈ ២

ឆ្នាំ ២០១១

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ការិយបរិច្ឆេទ ២០០៧**

# អារម្ភកថា

ប្រទេសកម្ពុជាទទួលបានសុខសន្តិភាព និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដោយសារការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍នូវគោលនយោបាយបង្រួបបង្រួមជាតិ និងយុទ្ធសាស្ត្រចតុកោណ ពិសេសការអនុវត្តន៍កម្មវិធីកំណែទម្រង់លើវិស័យជាមូលដ្ឋាន ជាអាទិ៍ កំណែទម្រង់លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍វិស័យឯកជន និងកំណែទម្រង់រដ្ឋបាលសាធារណៈ... ។

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសវនកម្មកំពូល ដែលបានបង្កើតឡើងនៅខែមីនា ឆ្នាំ២០០០ ដោយឆន្ទៈ និងការប្ដេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ក្នុងគោលបំណងដើម្បីអនុវត្តការងារត្រួតពិនិត្យ វាយតម្លៃ និងផ្ដល់អនុសាសន៍កែលំអនូវរាល់ចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងធ្វើរបាយការណ៍ស្ដីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងជូនទៅរាជរដ្ឋាភិបាល សំដៅរួមចំណែកក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារឲ្យមានភាពកាន់តែប្រសើរ និងប្រកបដោយការអភិវឌ្ឍន៍ ។

អាជ្ញាធរសវនកម្មជាតិផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះ បានលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារក្នុងការិយបរិច្ឆេទ២០០៧ របស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធមួយចំនួន ។

ការខិតខំប្រឹងប្រែងរបស់មន្ត្រីសវនកម្ម និងការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានបានជំរុញឲ្យអាជ្ញាធរសវនកម្មជាតិមានសក្ដានុពលក្នុងការអភិវឌ្ឍន៍ការងារ និង អនុវត្តផែនការយុទ្ធសាស្ត្រ២០០៧-២០១១ របស់ខ្លួនសម្រេចលទ្ធផលជាបន្តបន្ទាប់។ ចំពោះមុខ អាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពនៃការធ្វើសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចបាននូវស្តង់ដារសវនកម្ម ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិ ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងក្នុងក្របខ័ណ្ឌច្បាប់ ក៏ដូចជាក្របខ័ណ្ឌហិរញ្ញវត្ថុ សម្ភារៈ និងស្មារតី។ ម្យ៉ាងវិញទៀត ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការចំពោះអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (DANIDA) ធនាគារពិភពលោក (WB) ព្រមទាំងស្ថាប័នសវនកម្មកំពូលនានាដែលបានផ្ដល់ការគាំទ្រ និងជួយឧបត្ថម្ភក្នុងកិច្ចដំណើរការអភិវឌ្ឍការងារ និងសូមសរសើរដល់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ច ធ្វើឲ្យសម្រេច បាននូវស្នាដៃដ៏ឧត្ដុង្គឧត្ដមជូនជាតិមាតុភូមិ ។

ជាមួយនេះដែរ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីថ្លែងអំណរគុណចំពោះរាល់អង្គភាពរងសវនកម្ម និងសាធារណជនទាំងឡាយ ដែលបានសហការ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឲ្យវិស័យសវនកម្មកន្លងមក ។

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១

**អគ្គសវនករ**

**អ៊ុត ឈន**

# មាតិកា


ទំព័រ

**សេចក្តីសង្ខេប** ........ ០១

**១. សេចក្តីផ្តើម** ........ ០៣

១.១. លក្ខណៈទូទៅ ........ ០៣

១.២. ការអនុវត្តន៍ និងដែនកំណត់សវនកម្ម ........ ០៣

១.៣. គោលបំណងនៃការផ្សព្វផ្សាយ ........ ០៣

**២.ការគ្រប់គ្រងថវិកា** ........ ០៤

២.១. មូលដ្ឋានគតិយុត្តិនៃការអនុវត្តន៍ថវិកា ........ ០៤

២.២. កិច្ចប្រតិបត្តិការថវិកា ........ ០៥

**៣. លទ្ធផលសវនកម្ម** ........ ០៦

**៣.១. ការគ្រប់គ្រងថវិការដ្ឋបាលកណ្តាល** ........ ០៦

៣.១.១. ការត្រួតពិនិត្យឯកសារនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម ........ ០៦

៣.១.២. ការតាមដាន និងការគ្រប់គ្រងលើទំនិញនាំចូលតាមរបបអនុគ្រោះពន្ធ ........ ០៧

៣.១.៣. ការគ្រប់គ្រងប្រមូលចំណូលពន្ធ ........ ០៨

៣.១.៤. ការគ្រប់គ្រងសកម្មភាពអាជីវកម្មក្រុមហ៊ុន-សហគ្រាស ........ ០៩

៣.១.៥. ការគ្រប់គ្រងប្រមូលចំណូលពីសម្បទានរ៉ែ និងផលនេសាទសមុទ្រ ........ ១០

៣.១.៦. ការកត់ត្រាលើការចំណាយថវិកាជំពូក៦១ (សេវាខាងក្រៅ) ........ ១១

៣.១.៧. ការរៀបចំផែនការ និងការអនុវត្តន៍វិធីសាស្រ្តលទ្ធកម្ម ........ ១២

៣.១.៨. ការទូទាត់ការចំណាយប្រាក់បុរេប្រទាន ........ ១៣

៣.១.៩. ការគ្រប់គ្រងការប្រើប្រាស់អាជ្ញាប័ណ្ណសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសោតទស្សន៍ ..... ១៤

៣.១.១០. ការរក្សាទុកសាច់ប្រាក់ក្នុងបេឡា ........ ១៥

**៣.២. ការគ្រប់គ្រងថវិការាជធានី-ខេត្ត និងឃុំសង្កាត់** ........ ១៥

៣.២.១. ការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (ដីធ្លី-ផ្ទះសំបែង) ........ ១៥

៣.២.២. ការលើកលែងប្រាក់ពន្ធ និងប្រាក់ពន្ធបន្ថែមលើដីមិនបានប្រើប្រាស់ ........ ១៦

៣.២.៣. ការគ្រប់គ្រងចំណូលសម្រាប់ទម្រង់ការរដ្ឋបាល និងការអនុញ្ញាតរដ្ឋបាល ........ ១៧

៣.២.៤. ការប្រមូលចំណូល និងការកត់ត្រាចំណូលរបស់ឃុំ-សង្កាត់ ........ ១៨

៣.២.៥. ការបំបែកគម្រោងលទ្ធកម្មតម្រូវតាមសិទ្ធិសម្រេចរបស់ខេត្ត ........ ១៨

**៣.៣. ការអនុវត្តន៍គំរោងវិនិយោគ** ........ ១៩

ការវាយតម្លៃ និងការពន្យារសុពលភាពលើសំណើដេញថ្លៃ ........ ១៩

**៤. ការតាមដានលើការអនុវត្តន៍កែលំអតាមអនុសាសន៍សវនកម្ម** ........ ២១

**៥. សេចក្តីសន្និដ្ឋាន** ........ ២៣

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០០៧

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈមួយដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការការងារ និងមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧ នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។ សម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួន ដែលមានលទ្ធផលសង្ខេបដូចខាងក្រោម ៖

តាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រជាតិលើកទីពីរ និងយុទ្ធសាស្ត្រចតុកោណនាឆ្នាំ២០០៧នេះ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថេរភាពល្អ ដោយសម្រេចបាននូវកំណើនសេដ្ឋកិច្ច១០,២% ខ្ពស់ជាងការគ្រោងទុកដែលមាន៦,៥% ។

ការអនុវត្តន៍ចំណូលតាមរយៈរតនាគារជាតិក្នុងឆ្នាំសម្រេចបានចំនួន៤.២០២.០៧៣លានរៀល ស្មើនឹង១២០% នៃផែនការឆ្នាំដែលមានចំនួន៣.៥១២.៣០៦លានរៀល។ ទន្ទឹមនឹងលទ្ធផលដែលសម្រេចបាននេះ បើផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មបង្ហាញឲ្យឃើញថា នៅមានកម្រិតនៅឡើយ ដោយសារកត្តាមួយចំនួន មានជាអាទិ៍ ការត្រួតពិនិត្យលើឯកសារទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្មប្រព្រឹត្តទៅដោយពុំទាន់ពេញលេញ និងច្បាស់លាស់ ការត្រួតពិនិត្យ និងតាមដានទំនិញនាំចូលតាមរបបអនុគ្រោះពន្ធនានាពុំទាន់បានអនុវត្តដោយហ្មត់ចត់។ ការត្រួតពិនិត្យទំនិញ និងការបង្ក្រាបបទល្មើសគយដើមទីពុំទាន់បានប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញនាំចូលមួយចំនួនដែលពុំអាចបញ្ជាក់បាននូវថ្លៃទំនិញនាំចូលជាក់ស្តែង កំពុងត្រូវបានប្រើប្រាស់។ កិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាក្នុងការតាមដានសកម្មភាពអាជីវកម្មនាំចូល ការគ្រប់គ្រងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន-សហគ្រាស និងការចុះអាជីវកម្មដ្ឋានតាមរបបម៉ៅការក្នុងបញ្ជីពន្ធនៅមានកម្រិត។ ការវាយតម្លៃ និងកំណត់ថ្លៃឈ្នួលដីសម្បទានពុំទាន់បានប្រព្រឹត្តទៅឲ្យបានទាន់ពេលវេលា។ ការគ្រប់គ្រងប្រមូលចំណូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ពុំទាន់បានរលូន ដោយ គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ពុំទាន់បានបង្កើតបញ្ជីដីនៅតាមតំបន់រាជធានី-ខេត្ត ហើយការអនុវត្តន៍ទោសទណ្ឌចំពោះការមិនបានបង់ពន្ធដីធ្លីនៅមានកម្រិត។ ការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ(ដី-ផ្ទះ) ពុំទាន់បានពេញលេញលើមូលដ្ឋានតម្លៃទីផ្សារ។ ការគ្រប់គ្រងប្រមូលចំណូលពីសម្បទានរ៉ែនៅមានកម្រិត ដោយខ្វះវិធានការច្បាប់ចំពោះក្រុមហ៊ុន ឬអាជីវករដែលមិនបានអនុវត្តតាមច្បាប់ស្តីពីសម្បទានរ៉ែ។ ចំណូលផលនេសាទសមុទ្រប្រមូលពុំទាន់បានពេញលេញ ដោយសារ

ការពុំទាន់បានបង្កើតផែសម្រាប់ផ្ទេរផលនេសាទ។ ចំណូលសម្រាប់ទម្រង់ការរដ្ឋបាល និងការអនុញ្ញាតរដ្ឋបាលរបស់បណ្តារាជធានី-ខេត្តពុំទាន់បានប្រមូលឲ្យស្របតាមច្បាប់កំណត់ ការប្រមូល និងការកត់ត្រាចំណូលរបស់ឃុំ-សង្កាត់ពុំទាន់បានពេញលេញ... ។

ការអនុវត្តន៍ចំណាយតាមរយៈរតនាគារជាតិក្នុងឆ្នាំសម្រេចបានចំនួន៣.៤១៧.១៨៧លានរៀល ស្មើនឹង៩៤% នៃផែនការដែលមានចំនួន៣.៦៣១.២៨៤លានរៀល។ ក្នុងការអនុវត្តន៍ចំណាយថវិកានេះ មានចំណុចគួរឲ្យកត់សម្គាល់មួយចំនួន ជាអាទិ៍ ការកត់ត្រាលើការចំណាយថវិកាសម្រាប់សេវាខាងក្រៅមិនទាន់ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ។ នៅបន្តមានការបញ្ជូនអាណត្តិបើកប្រាក់យ៉ាងគំហុកទៅឲ្យអគ្គនាយកដ្ឋានរតនាគារជាតិធ្វើការទូទាត់នៅចុងឆ្នាំ និងក្រោយថ្ងៃឱសានវាទបិទបញ្ជីការដកចំណូលយកទៅចំណាយ ដោយពុំមានកត់ត្រាចូលក្នុងថវិកា ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានសមតុល្យនិងគ្នា គឺចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះ ក្នុងឆ្នាំសម្រេចបានចំនួន១.៦៨២.២៨៩លានរៀល ស្មើនឹង១៥១% នៃផែនការដែលមានចំនួន១.១១០.០០០លានរៀល។

ចំពោះការតាមដានបំណុលបានបង្ហាញឲ្យឃើញថា មានបំណុលមួយចំនួនពុំត្រូវបានធ្វើការកត់ត្រាតាមដានជាលក្ខណៈប្រមូលផ្តុំនៅអគ្គនាយកដ្ឋានរតនាគារជាតិនោះទេ ដែលបង្កឲ្យមានការលំបាកក្នុងការតាមដាន និងត្រួតពិនិត្យឲ្យបានច្បាស់លាស់ ។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

តាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ក្នុងនោះរួមមាន ការធ្វើសវនកម្មលើបញ្ជិកាគណនេយ្យគណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារអាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចំរុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនផង។

ក្រៅអំពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានតួនាទីធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ហើយត្រូវធ្វើរបាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងធ្វើការផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់ ។

### ១.២. ការអនុវត្តន៍ និងដែនកំណត់សវនកម្ម

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតដល់ឆ្នាំ២០០៩ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មនៅតាមបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ សរុបមានចំនួន៥៥៨ របាយការណ៍ ពិសេស ការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅ របស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ។ សម្រាប់ការិយបរិច្ឆេទ២០០៧ សរុបមានចំនួន៧៥របាយការណ៍ ក្នុងនោះបញ្ហាគួរឲ្យកត់សម្គាល់ ដូចបានដកស្រង់ខ្លឹមសារលើកឡើងក្នុងចំណុចទី៣ នៃរបាយការណ៍នេះ ដែលស្របតាមមាត្រា២៩ និងមាត្រា៣៧ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ។

អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅដែលតម្រូវឲ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្ម ដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗដើម្បីទទួលបាននូវភស្តុតាងសវនកម្ម និងតាមដានការអនុវត្តន៍កែលំអតាមអនុសាសន៍សវនកម្ម ។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ គឺដើម្បីចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា

តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតផ្សេងៗ ដែលបានអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលំអ សំដៅធ្វើឲ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួង-ស្ថាប័ន មានភាពកាន់តែប្រសើរ និងឈានទៅរកអភិបាលកិច្ចល្អ ។

អាជ្ញាធរសវនកម្មជាតិអនុវត្តកាតព្វកិច្ចផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ ដោយអនុលោមតាមមាត្រា២៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា " របាយការណ៍ដែលធ្វើដោយអគ្គសវនករ ត្រូវបានចាត់ទុកជាឯកសារសាធារណៈ " ។ អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន-សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងពេលដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះ ទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅជាយថាហេតុ ។

## ២. ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តិនៃការអនុវត្តន៍ថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០០៧នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួន មានជាអាទិ៍ ៖

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ០១ ន.ស ៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ។
- អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ បានបញ្ជាក់ថា សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ ត្រូវបានដាក់ជូនសភាជាតិមុនដំណាច់ឆ្នាំ។ សេចក្តីព្រាងច្បាប់នេះ ផ្អែកលើគណនីទូទៅនៃការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និងលើរបាយការណ៍គ្រប់គ្រងទាំងឡាយដែលរៀបចំដោយក្រសួង-ស្ថាប័ន និងខេត្ត-ក្រុងនានា ... ។
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ។
- អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ។
- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ត្រូវបានរាជរដ្ឋាភិបាលបញ្ជូនមកដល់អាជ្ញាធរសវនកម្មជាតិ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ សម្រាប់ធ្វើសវនកម្ម ។

- របាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ត្រូវបានអាជ្ញាធរសវនកម្មជាតិផ្ញើជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលដើម្បីជូនជ្រាបជាព័ត៌មាន នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ។

## ២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០០៧ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តន៍ចំណូល-ចំណាយតាមរយៈរតនាគារជាតិ និងលទ្ធផលការអនុវត្តន៍គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០០៦ | ២០០៧ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4 = (3/2)* |
| I. សរុបចំណូល | **4.728.052** | **4.622.306** | **5.884.362** | **127%** |
| - ចំណូលចរន្ត | 2.881.720 | 3.252.173 | 4.012.105 | 123% |
| - ចំណូលមូលធន | 515.290 | 260.133 | 189.968 | 73% |
| - ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 1.331.042 | 1.110.000 | 1.682.289 | 151% |
| II. សរុបចំណាយ | **4.144.089** | **4.741.284** | **5.099.476** | **107%** |
| - ចំណាយចរន្ត | 2.366.553 | 2.956.151 | 2.873.903 | 97% |
| - ចំណាយមូលធន | 446.494 | 675.133 | 543.284 | 80% |
| - ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 1.331.042 | 1.110.000 | 1.682.289 | 151% |

## ៣. លទ្ធផលសវនកម្ម

ឆ្លងតាមការធ្វើសវនកម្មលើការគ្រប់គ្រងចំណូល-ចំណាយថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារឆ្នាំ២០០៧ និងឆ្នាំពាក់ព័ន្ធ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន អង្គភាពពាក់ព័ន្ធមួយចំនួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញបញ្ហាគួរឲ្យកត់សម្គាល់ និងបានដកស្រង់នូវចំណុចមួយចំនួនមកបង្ហាញ រួមមានដូចខាងក្រោម ៖

### ៣.១. ការគ្រប់គ្រងថវិការដ្ឋបាលកណ្តាល

#### ៣.១.១. ការត្រួតពិនិត្យឯកសារនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម

ការធ្វើចរាចរទំនិញគ្រប់ប្រភេទ ពិសេស ការនាំចូលត្រូវទទួលបានការចាប់អារម្មណ៍ពីគ្រប់មជ្ឈដ្ឋាន។ នៅក្នុងឆ្នាំ២០០៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ០០៩ សហវ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម ដោយបញ្ជាក់ថា ទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម គឺជាទំនិញដែលត្រូវបាននាំចូលម្តងម្កាល ដោយអ្នកដំណើរ ឬប្រជាពលរដ្ឋដែលមានលំនៅដ្ឋានជាអចិន្ត្រៃយ៍ក្នុងតំបន់ព្រំដែនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងប្រើប្រាស់ក្នុងតំបន់ព្រំដែន។ ចំពោះទំនិញមានលក្ខណៈពាណិជ្ជកម្មត្រូវបានធ្វើឡើងដោយបុគ្គលដែលមានលេខអត្តសញ្ញាណកម្មអាករលើតម្លៃបន្ថែម និងប័ណ្ណប៉ាតង់នៅឆ្នាំចុងក្រោយ។ ប៉ុន្តែតាមការធ្វើតេស្តលើឯកសារ (ប្រតិវេទន៍) ទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្មឆ្នាំ២០០៧ នៅសាខាគយ និងរដ្ឋាករខេត្តកំពង់ចាម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សំណុំឯកសារទំនិញនាំចូលទាំងនោះពុំមានលក្ខណៈពេញលេញ និងច្បាស់លាស់ឡើយ ដោយក្នុងនោះសំណុំឯកសារមួយចំនួនពុំមានភ្ជាប់ និងបំពេញលេខអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនអ្នកនាំចូលតាមការតម្រូវនោះទេ ហើយក្នុងនោះដែរមានឈ្មោះអ្នកនាំចូលដដែលៗ។ កត្តាទាំងនេះ អាចសន្និដ្ឋានបានថា គឺជាការនាំចូលទំនិញដែលពុំមែនសុទ្ធតែគ្មានលក្ខណៈពាណិជ្ជកម្មនោះទេ ។

ដោយហេតុដូចនេះ ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលចំណូល និងមានសមធម៌ក្នុងការធ្វើពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាធ្វើការត្រួតពិនិត្យលើឯកសារនាំចូលឲ្យបានហ្មត់ចត់ និងអនុវត្តឲ្យស្របតាមសារាចរណែនាំខាងលើ ។

ឆ្លើយតបនឹងការលើកឡើងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសូមឯកភាពលើមតិ និងអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិដែលបានលើកឡើងនេះ។ ប៉ុន្តែក្នុងការចែកឲ្យដាច់រវាងការនាំចូលទំនិញមានលក្ខណៈពាណិជ្ជកម្ម និងគ្មានលក្ខណៈពាណិជ្ជកម្មឲ្យបានទាំងស្រុងនោះពិតជាមិនសាមញ្ញពេកទេ។ តែទោះជាយ៉ាងណាក្តី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចាត់វិធានការសមស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ដើម្បីពង្រឹងប្រសិទ្ធភាពនៃការនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម តាមបញ្ញត្តិសារាចរណែនាំលេខ០០៩ សហវ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការ

គ្រប់គ្រងទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម។ ទន្ទឹមនេះ ក្រសួងក៏បានដាក់ចេញវិធានការមួយចំនួនឲ្យអនុវត្តផងដែរ រួមមាន ៖

- ការធ្វើវិមជ្ឈការការងារកំណត់តម្លៃគិតពន្ធគយ ជូនមន្ត្រីកំណត់តម្លៃគិតពន្ធគយប្រចាំការនៅអង្គភាពគយ និងរដ្ឋាករមូលដ្ឋាននានា រួមទាំងភូមិសាស្ត្រខេត្តកំពង់ចាមផងដែរ

- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជានឹងធ្វើសវនកម្មផ្ទៃក្នុង ក្នុងអង្គភាពបន្ថែមទៀត ដើម្បីវាយតម្លៃពីកិច្ចដំណើរការនេះ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបង្កើនការតាមដានត្រួតពិនិត្យទៅលើកិច្ចដំណើរការ និងសំណុំឯកសារប្រតិវេទន៍ ឲ្យបានដិតដល់ និងស៊ីជម្រៅថែមទៀត ដើម្បីជំរុញការអនុវត្តន៍ការងារនេះឲ្យបានកាន់តែល្អប្រសើរ និងស្របតាមសារាចរណែនាំខាងលើ ។

## ៣.១.២. ការតាមដាន និងគ្រប់គ្រងលើទំនិញនាំចូលតាមរបបអនុគ្រោះពន្ធ

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រគល់តួនាទី និងភារកិច្ចក្នុងការដឹកនាំ និងគ្រប់គ្រងប្រមូលចំណូលពន្ធបង់ចូលថវិការដ្ឋ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានភារកិច្ចតាមដាន ត្រួតពិនិត្យលើការប្រើប្រាស់សម្ភារៈ បរិក្ខារ និងទំនិញគ្រប់ប្រភេទ ដែលទទួលបានការអនុគ្រោះពន្ធផ្សេងៗពីរាជរដ្ឋាភិបាល ដោយរួមទាំងការចុះតាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍ ឬលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋាន ឬពាណិជ្ជកម្មនានា ស្របតាមនីតិវិធីនៃច្បាប់ជាធរមាន...។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ជារៀងរាល់ឆ្នាំរាជរដ្ឋាភិបាលបានអនុវត្តរបបអនុគ្រោះពន្ធ (ពន្ធជាបន្ទុករបស់រដ្ឋ) លើការនាំចូលសម្ភារៈ បរិក្ខារ និងវត្ថុធាតុដើមផ្សេងៗជាច្រើនដល់អង្គការ ស្ថាប័ន និងក្រុមហ៊ុនវិនិយោគនានា ដែលបាន និងកំពុងមានសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពុំមានរបាយការណ៍ ឬ កំណត់ហេតុស្តីពីការចុះត្រួតពិនិត្យ ឬឃ្លាំមើលតាមបណ្តាអាជីវកម្មដ្ឋាន ឬពាណិជ្ជកម្មណាមួយឡើយ ។

អាស្រ័យដូចនេះ ដើម្បីអនុវត្តការងារតាមដានត្រួតពិនិត្យលើការនាំចូល និងការប្រើប្រាស់សម្ភារៈ បរិក្ខារ និងទំនិញក្រោមរបបអនុគ្រោះពន្ធផ្សេងៗឲ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានហ្មត់ចត់ថែមទៀតលើការតាមដានត្រួតពិនិត្យទំនិញនាំចូលតាមរបបអនុគ្រោះពន្ធ ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសូមឯកភាពលើមតិ និងអនុសាសន៍ដែលបានលើកឡើងនេះ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមរៀបរាប់នូវវឌ្ឍនភាពមួយចំនួនពាក់ព័ន្ធនឹងការពង្រឹងប្រសិទ្ធភាព និងការតាមដានគ្រប់គ្រងជាក្រោយ លើទំនិញនាំចូលតាមរបបគយនានា ដូចខាងក្រោម ៖

- ពិនិត្យលើទិដ្ឋភាពច្បាប់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានចូលរួមកសាង និងដាក់ឲ្យដំណើរការនូវបទប្បញ្ញត្តិនានា ពាក់ព័ន្ធនឹងការធ្វើសវនកម្មក្រោយពេលទំនិញ

បញ្ចេញពីគយ (Post Clearance Audit) ជាពិសេស ប្រកាសស្តីពីការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដោយអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា សេចក្តីណែនាំជំហានដំបូងស្តីពីការធ្វើ PCA ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងសេចក្តីណែនាំស្តីពីការធ្វើ PCA ក្នុងការិយាល័យគយ។ បទប្បញ្ញត្តិទាំងនេះ បានបង្កើត និងប្រគល់ភារកិច្ចច្បាស់លាស់ជូនអង្គភាពនៅតាមសាខាគយ និងរដ្ឋាកររាជធានី-ខេត្ត ការិយាល័យត្រួតពិនិត្យនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអង្គភាព PCA នៃការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ ដើម្បីធានាប្រសិទ្ធភាពការងារនេះ

- បានបណ្តុះបណ្តាលមន្ត្រីគយ និងរដ្ឋាករនូវជំហាន PCA ចំនួនប្រមាណ១០០ នាក់ និងបានប្រគល់ភារកិច្ចជាមន្ត្រីសវនកម្មគយចំនួន ២៥នាក់ រួចមកហើយ

- បានដាក់ដំណើរការអង្គភាពមូលដ្ឋាននៅសាខាគយ និងរដ្ឋាករខេត្តព្រះសីហនុរួចហើយ និងឈានទៅដាក់ឲ្យដំណើរការនៅតាមសាខា និងការិយាល័យគយ និងរដ្ឋាករផ្សេងៗ ឲ្យបានរួចរាល់នាពេលខាងមុខ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមធ្វើការបញ្ជាក់ឡើងវិញថា អ្វីដែលអាជ្ញាធរសវនកម្មជាតិលើកឡើង គឺអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាពុំមានរបាយការណ៍ ឬ កំណត់ហេតុស្តីពីការអនុវត្តន៍តួនាទីរបស់ខ្លួនក្នុងការចុះត្រួតពិនិត្យ ឬឃ្លាំមើលតាមបណ្តាអាជីវកម្មដ្ឋាន ឬពាណិជ្ជកម្មណាមួយនូវទំនិញនាំចូលតាមរបបអនុគ្រោះពន្ធ ។

## ៣.១.៣. ការគ្រប់គ្រងប្រមូលចំណូលពន្ធ

ផ្អែកតាមសារាចរណែនាំលេខ ០០២ ស.រ.សហវ.ពជ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីវិធានការត្រួតពិនិត្យសារពើពន្ធ បានបញ្ជាក់ថា នាយកដ្ឋានលទ្ធកម្មសាធារណៈ នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវធ្វើកិច្ចសហការផ្តល់ព័ត៌មាន និងឯកសារច្បាប់ចម្លងផ្សេងៗ ពាក់ព័ន្ធនឹងកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ជួសជុលសាងសង់ សេវា ឯកសារនៃការអនុវត្តន៍គម្រោងទទួលបានពីហិរញ្ញប្បទានបរទេស និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ។ ប៉ុន្តែក្នុងការអនុវត្តន៍កន្លងមក អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពទាំងបីខាងលើពុំទាន់បានធ្វើកិច្ចសហការអនុវត្តវិធានការនេះឲ្យបានពេញលេញនៅឡើយ ។

អាស្រ័យហេតុនេះ ដើម្បីគ្រប់គ្រងការប្រមូលចំណូលសារពើពន្ធឲ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអង្គភាពពាក់ព័ន្ធទាំងបីនេះសហការគ្នាឲ្យបានល្អប្រសើរថែមទៀត ។

ឆ្លើយតបនឹងការលើកឡើងខាងលើ កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានធ្វើរបាយការណ៍លទ្ធផលសរុបអំពីស្ថានភាពគ្រប់គ្រងប្រមូលពន្ធ និងការធ្វើសវនកម្មសហគ្រាស។ ដើម្បីពង្រឹងការអនុវត្តន៍សារាចរស្តីពីវិធានការត្រួតពិនិត្យខាងលើ និងអនុវត្តអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំឲ្យអគ្គនាយកដ្ឋានពន្ធដារ

រៀបចំរបាយការណ៍អំពីការប្រើប្រាស់ព័ត៌មាន ឬទិន្នន័យទទួលបានពីប្រភពនីមួយៗឲ្យបានជាក់លាក់ សំដៅបង្កើនកិច្ចសហប្រតិបត្តិការឲ្យបានកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា កិច្ចការនេះនឹងប្រព្រឹត្តទៅប្រកបដោយលក្ខណៈល្អប្រសើរថែមទៀត ។

### ៣.១.៤. ការគ្រប់គ្រងសកម្មភាពអាជីវកម្មក្រុមហ៊ុន-សហគ្រាស

អគ្គនាយកដ្ឋានពន្ធដារមានតួនាទីភារកិច្ចប្រមូលចំណូលពន្ធ និងធ្វើការអនុវត្តន៍វិធានតឹងទារ ស៊ើបអង្កេតចំពោះអ្នកជាប់ពន្ធ និងត្រូវរៀបចំរក្សាទុកដាក់សំណុំឯកសារលិខិតប្រកាសអ្នកជាប់ពន្ធ និងពិនិត្យលើភាពមិនប្រក្រតីលើលិខិតប្រកាស ដើម្បីធ្វើសវនកម្មលើលិខិតស្នាម ឬលើកសំណើធ្វើសវនកម្ម កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងផ្គុំព័ត៌មាន ដើម្បីធ្វើសវនកម្មអ្នកជាប់ពន្ធឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ប៉ុន្តែក្នុងការអនុវត្តន៍កន្លងមក អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារពុំទាន់អនុវត្តបានពេញលេញតាមតួនាទី និងភារកិច្ចរបស់ខ្លួននៅឡើយ ជាអាទិ៍ដូចជា ៖

- ផ្អែកតាមការធ្វើតេស្តលើក្រុមហ៊ុន-សហគ្រាសចំនួន២៣ ក្នុងចំណោមក្រុមហ៊ុន-សហគ្រាសចំនួន៨.៦៧៤ គឺមានក្រុមហ៊ុន-សហគ្រាសចំនួន១៣ បានប្រកាសផលរបរមិនទាន់ត្រឹមត្រូវ។ ដោយឡែកចំពោះក្រុមហ៊ុន-សហគ្រាសដែលបានប្រកាសឈប់ ផ្អាក និងក្រុមហ៊ុន-សហគ្រាសបាត់ខ្លួនសរុបចំនួន២១៦ ក្រុមហ៊ុន-សហគ្រាស ក្នុងនោះមានក្រុមហ៊ុនសហគ្រាសចំនួន៣២ បានធ្វើសកម្មភាពនាំទំនិញចូលតាមរយៈអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។
- ការប្រមូលផ្តុំព័ត៌មានពីអង្គភាពពាក់ព័ន្ធអនុវត្តមិនបានទៀងទាត់ យឺតយ៉ាវ និងមិនសមស្របតាមស្ថានភាពអាជីវកម្មជាក់ស្តែង ។
- តាមលទ្ធផលនៃការធ្វើសវនកម្មកំណត់ពន្ធឡើងវិញក្នុងឆ្នាំ២០០៧ ដែលសម្រេចបានចំនួន ១.១១៦ ក្រុមហ៊ុន-សហគ្រាស ក្នុងនោះភាគច្រើនស្ថិតក្នុងឆ្នាំចាស់ៗ និងមួយចំនួនជាប្រភេទក្រុមហ៊ុន-សហគ្រាសបាត់ខ្លួន រកម្ចាស់មិនឃើញ ឬគ្មានអសយដ្ឋានច្បាស់លាស់ ហើយត្រូវបានកំណត់ពន្ធឡើងវិញតាមរយៈនៃការផ្ញើសំបុត្រប្រៃសណីយ៍ និងការកំណត់ពន្ធឯកតោភាគី ។

អាស្រ័យហេតុនេះ ដើម្បីឲ្យការកំណត់ពន្ធឡើងវិញបានទាន់ពេលវេលា និងកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអគ្គនាយកដ្ឋានពន្ធដារពង្រឹងការតាមដាន និងត្រួតពិនិត្យសកម្មភាពអាជីវកម្មក្រុមហ៊ុន-សហគ្រាសឲ្យបានជាប្រចាំ ច្បាស់លាស់ និងទាន់ពេលវេលា ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសូមឯកភាពតាមរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិ អំពីតួនាទីភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្នុងករណីដែលរដ្ឋបាលសារពើពន្ធពិនិត្យឃើញភាពមិនប្រក្រតីនៃ

ព័ត៌មាន ឬទិន្នន័យក្នុងលិខិតប្រកាសរបស់ក្រុមហ៊ុន-សហគ្រាស រដ្ឋបាលសារពើពន្ធត្រូវកំណត់ឈ្មោះក្រុមហ៊ុន-សហគ្រាសទាំងនេះ ក្នុងកម្មវិធីសវនកម្មរបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមជម្រាបថា ក្នុងការអនុវត្តន៍របបឆ្លើយប្រកាស រដ្ឋបាលសារពើពន្ធទទួលយកការឆ្លើយប្រកាសរបស់សហគ្រាស ប៉ុន្តែមានសិទ្ធិធ្វើសវនកម្មជាក្រោយ។ ចំពោះក្រុមហ៊ុន-សហគ្រាសទាំង១៣ ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើងក្នុងរបាយការណ៍ អគ្គនាយកដ្ឋានពន្ធដារបានដាក់ក្នុងកម្មវិធីសវនកម្មសម្រាប់ឆ្នាំ២០០៨រួចហើយ ក្រោយពេលដែលប្រមូលបានព័ត៌មាន ឬទិន្នន័យសហគ្រាសទាំងនោះ ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិសូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុណែនាំឲ្យអគ្គនាយកដ្ឋានពន្ធដារយកចិត្តទុកដាក់បង្កើនការត្រួតពិនិត្យ និងតាមដានសកម្មភាពអាជីវកម្មក្រុមហ៊ុន-សហគ្រាសដទៃទៀតឲ្យបានទាន់ពេលវេលា ។

### ៣.១.៥. ការគ្រប់គ្រងប្រមូលចំណូលពីសម្បទានរ៉ែ និងផលនេសាទសមុទ្រ

បទបញ្ជាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំនូវការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយផ្អែកទៅលើកិច្ចសន្យាដែលក្រសួង-ស្ថាប័ន សាលាខេត្ត-ក្រុង បានចុះហត្ថលេខាជាមួយរូបវន្តបុគ្គល នីតិបុគ្គលឯកជន ឬនីតិបុគ្គលសាធារណៈ។ តាមការធ្វើសវនកម្មនៅក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនសម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួង-ស្ថាប័នមួយចំនួន ពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំទាន់សហការអនុវត្តគ្រប់គ្រងប្រមូលចំណូលមិនមែនសារពើពន្ធឲ្យពេញលេញនៅឡើយ ជាអាទិ៍ ៖

- **ការគ្រប់គ្រងអាជីវកម្មរ៉ែ** : ការមិនទាន់ចាត់វិធានការចំពោះក្រុមហ៊ុន ឬអាជីវករដែលមិនបានគោរពតាមលក្ខខណ្ឌ ឬបាត់បង់ភាពស្របច្បាប់ក្នុងការធ្វើអាជីវកម្ម ។
- **ការគ្រប់គ្រងផលនេសាទ** : ការអនុវត្តន៍ប្រមូលចំណូលពីសម្បទាននេសាទពុំទាន់ពេញលេញ និងអស់លទ្ធភាព ដោយការគ្រប់គ្រងផលនេសាទសមុទ្រអនុវត្តមិនស្របតាមច្បាប់ជលផល ដែលតម្រូវឲ្យអាជីវករនេសាទសមុទ្រផ្ទេរផលនេសាទនៅតាមកំពង់ផែនេសាទក្រោមការអនុញ្ញាតរបស់រដ្ឋបាលជលផល ប៉ុន្តែជាក់ស្តែងការប្រមូលចំណូលនេះបែរជាយកតាមប្រភេទឧបករណ៍នេសាទទៅវិញ។ តាមទិន្នន័យផលនេសាទបង្ហាញឲ្យឃើញថា បរិមាណផលនេសាទសមុទ្រស្មើនឹង៥០% នៃបរិមាណផលនេសាទទឹកសាប ប៉ុន្តែចំណូលប្រមូលបានពីដែននេសាទសមុទ្រគឺរដ្ឋបាលជលផលអនុវត្តមិនទាន់អស់លទ្ធភាពនៅឡើយ ។

អាស្រ័យហេតុនេះ ដើម្បីបង្កើនចំណូលមិនមែនសារពើពន្ធ ដូចជា អាជីវកម្មរ៉ែ ឬផលនេសាទឲ្យបានល្អប្រសើរថែមទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសហការជាមួយនឹងសាមីក្រសួង ពង្រឹងការគ្រប់គ្រងប្រមូលចំណូលផ្នែកនេះថែមទៀត ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺ ដូចខាងក្រោម ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងខិតខំពង្រឹងការងារសហការជាមួយនឹងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីចាត់វិធានការចំពោះក្រុមហ៊ុន ឬអាជីវករ ដែលមិនបានគោរពតាមលក្ខខណ្ឌ ឬបាត់បង់ភាពស្របច្បាប់ក្នុងការធ្វើអាជីវកម្មឲ្យបានសមស្របតាមមាត្រាទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងបន្តសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពង្រឹងការប្រមូលចំណូល និងការគ្រប់គ្រងចំណូលផ្នែកនេះ ឲ្យកាន់តែមានប្រសិទ្ធភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការតាមដានការអនុវត្តន៍ ជាបន្តទៀត ។

### ៣.១.៦. ការកត់ត្រាលើការចំណាយថវិកាជំពូក៦១ (សេវាខាងក្រៅ)

តាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋបានបញ្ជាក់ថា ការចំណាយថវិកាជំពូក៦១ (សេវាខាងក្រៅ) គឺជាសេវាដែលផ្តល់ដោយសហគ្រាស ឬក្រុមហ៊ុនឯកជន ជារូបវន្តបុគ្គល ឬនីតិបុគ្គល។ ប៉ុន្តែតាមការពិនិត្យរបាយការណ៍ចំណាយវិនិយោគលើការថែទាំ និងជួសជុល ផ្លូវ ផ្លូវលំ ស្ពាន និងលូ នៅនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថាការចំណាយលើការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ ដែលអនុវត្តដោយភ្នាក់ងាររបស់រដ្ឋត្រូវបានកត់ត្រាក្នុងជំពូក៦១ (សេវាខាងក្រៅ) មិនស្របតាមខ្លឹមសារខាងលើ ដែលត្រូវកត់ត្រាក្នុងជំពូក៦០ (ការទិញ) និងជំពូក៦៤ (សោហ៊ុយបុគ្គលិក) ។

អាស្រ័យហេតុនេះ ដើម្បីឲ្យកិច្ចបញ្ជីកាគណនេយ្យមានលក្ខណៈពេញលេញ និងស្របតាមគោលការណ៍គណនេយ្យសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអង្គភាពក្រោមឱវាទ និងក្រសួង-ស្ថាប័ននានា អនុវត្តឲ្យបានត្រឹមត្រូវតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថាជារួមបញ្ហានេះបានឆ្លងកាត់ការពិភាក្សាគ្នាយ៉ាងច្រើននៅផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការបំភ្លឺអំពីមូលហេតុនៃការកត់ត្រាចំណាយក្នុងគណនី ៦១ ដូចតទៅ ៖

- ក្នុងករណីក្រសួងសាធារណការ និងដឹកជញ្ជូន យកថវិកាទៅទិញសម្ភារៈទុកក្នុងឃ្លាំង ហើយក្រសួងបើកសម្ភារៈទាំងនោះទៅឲ្យអង្គភាពក្រោមឱវាទប្រើប្រាស់នៅពេលមានសេចក្តីត្រូវការជួសជុល និងថែទាំផ្លូវនោះ ទើបចំណាយត្រូវកត់ត្រាក្នុងជំពូក៦០។ ការគ្រប់គ្រងដូចនេះ ដោយផ្អែកលើធាតុចូល (Input-based Management) មិនត្រូវបានយកមកអនុវត្តទេ ព្រោះបើទោះបីជាយើងអាចធានាប្រសិទ្ធភាពអំពីតម្លៃឯកតានៃមធ្យោបាយ និងសម្ភារៈ យើងមិនអាចធានាប្រសិទ្ធភាពលើការគ្រប់គ្រងខាងបរិមាណនៃការប្រើប្រាស់ជាក់ស្តែងបានទេ ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូនបានឯកភាពគ្នា អនុវត្តតាមវិធីសាស្ត្រគ្រប់គ្រងដោយផ្អែកលើលទ្ធផល (Result-based Management)

វិញ។ ការងារនេះ រាប់ចាប់តាំងពីការងារថែទាំជាប្រចាំឡើងទៅ ឧទាហរណ៍ ដើម្បីថែទាំផ្លូវមួយខ្សែឲ្យនៅល្អជាប្រចាំ (តាមបទដ្ឋានបច្ចេកទេសកំណត់) តើក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវការថវិកាប៉ុន្មាន។ ការងារនេះ តម្រូវឲ្យក្រសួងសាធារណការ និងដឹកជញ្ជូនលើកគម្រោងលំអិត និងឆ្លងកាត់ការអនុវត្តន៍នីតិវិធីហិរញ្ញវត្ថុនានាជាធរមាន។ ក្រសួងសាធារណការ និងដឹកជញ្ជូន មិនចាំបាច់រាយការណ៍ឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីបរិមាណនៃការប្រើប្រាស់ធាតុចូលជាក់ស្តែងនោះទេ បញ្ហាសំខាន់គឺក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលខុសត្រូវក្នុងការសម្រេចឲ្យបានលទ្ធផលតាមការគ្រោងទុក។ ក្នុងន័យនេះ បើទោះបីជាការងារអនុវត្តដោយបណ្តាអង្គភាពក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូនក៏ដោយចំណាយមិនអាចកត់ត្រាក្នុងជំពូក ៦០ ទេ គឺត្រូវតែកត់ត្រាក្នុងជំពូក ៦១។ ទោះជាយ៉ាងណាក៏ដោយ អង្គភាពទាំងនោះ (អង្គភាពអនុវត្តគម្រោងក្រោមឱវាទក្រសួងសាធារណការ និងដឹកជញ្ជូន) ត្រូវតែមានកិច្ចបញ្ជីកាគណនេយ្យច្បាស់លាស់ និងស្ថិតក្រោមកម្មវត្ថុនៃការធ្វើសវនកម្មជាយថាហេតុ ដោយស្ថាប័នមានសមត្ថកិច្ច ។

ផ្អែកតាមការបំភ្លឺខាងលើនេះ អាជ្ញាធរសវនកម្មជាតិសូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ សំដៅឲ្យការកត់ត្រាចំណាយលើផ្នែកនេះមានលក្ខណៈកាន់តែច្បាស់លាស់ ។

### ៣.១.៧. ការរៀបចំផែនការ និងការអនុវត្តន៍វិធីសាស្ត្រលទ្ធកម្ម

តាមគោលការណ៍លទ្ធកម្មសាធារណៈ ស្ថាប័នអនុវត្តលទ្ធកម្ម ចាំបាច់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈនៅសប្តាហ៍ទី១ ខែមករា នៃឆ្នាំសារពើពន្ធ ស្របតាមគំរូដែលបានផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៧ មានស្ថាប័នអនុវត្តលទ្ធកម្មចំនួន ៥៧ ក្នុងចំណោម៨៣អង្គភាព នៃក្រសួង-ស្ថាប័ន រាជធានី-ខេត្ត និងសហគ្រាសសាធារណៈ បានរៀបចំផែនការលទ្ធកម្មរួចរាល់ ហើយបានផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើសពីនេះទៀត នៅក្នុងការអនុវត្តន៍វិធីសាស្ត្រលទ្ធកម្មសាធារណៈ គឺមាន៧៣ករណី អនុវត្តមិនបានត្រឹមត្រូវ ដោយបានបង្វែពីការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ មកអនុវត្តវិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងក្នុងស្រុក និងចុះកិច្ចសន្យាផ្ទាល់ ។

អាស្រ័យហេតុនេះ ដើម្បីឲ្យផែនការលទ្ធកម្មទទួលបានជោគជ័យ និងស្របតាមវិធីសាស្ត្រលទ្ធកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍លទ្ធកម្មសាធារណៈ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺថា ៖

ក- ឆ្នាំ២០០៧ ជាឆ្នាំដំបូងបំផុតក្នុងប្រទេសកម្ពុជាយើង ដែលតម្រូវឲ្យគ្រប់ស្ថាប័នអនុវត្តលទ្ធកម្ម រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់ខ្លួន។ ជំនាញនៃការរៀបចំមិនទាន់មានបទពិសោធន៍ កិច្ចសហប្រតិបត្តិការផ្ទៃក្នុងមិនទាន់រលូនល្អ ដែលនាំឲ្យការរៀបចំផែនការនេះ

មិនអាចបានត្រឹមត្រូវទាន់ពេលវេលា ប៉ុន្តែនៅឆ្នាំទីពីរ (២០០៨) មានតែ៤-៥ស្ថាប័នប៉ុណ្ណោះ ដែលរៀបចំមិនទាន់បាន ។

ខ- អង្ករ ប្រេងឥន្ធនៈ ឯកសណ្ឋាន ឱសថ (ផលិតក្នុងស្រុក) ការបោះពុម្ពផ្សេងៗ ជាផលិតផលមានស្រាប់ក្នុងស្រុក ដែលមានតែក្រុមហ៊ុនផ្គត់ផ្គង់ក្នុងស្រុកចាប់អារម្មណ៍ចូលរួម ដេញថ្លៃ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងធ្វើការពិនិត្យកំណត់ឡើងវិញនូវមុខសញ្ញា លទ្ធកម្មណាខ្លះ ដែលមិនគួរអនុវត្តវិធីសាស្ត្រលទ្ធកម្មដេញថ្លៃដោយការប្រកួតប្រជែងជា លក្ខណៈអន្តរជាតិ និងកម្រិតទឹកប្រាក់នៃគម្រោងចំណាយដែលសមស្របត្រូវអនុវត្តវិធីសាស្ត្រ លទ្ធកម្មការដេញថ្លៃ ដោយការប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។ មានមុខសញ្ញាលទ្ធកម្ម ខ្លះ ដូចជា ឱសថមួយចំនួននាំចូលពីក្រៅប្រទេសជាតម្រូវការចាំបាច់បន្ទាន់ ដែលជាហេតុនាំ ឲ្យការផ្សព្វផ្សាយមានរយៈពេលខ្លី ។

គ- អនុលោមតាមគោលការណ៍លទ្ធកម្មសាធារណៈ វិធីសាស្ត្រលទ្ធកម្មចុះកិច្ចសន្យា ផ្ទាល់ មិនកម្រិតទឹកប្រាក់ មិនតម្រូវឲ្យមានក្នុងផែនការលទ្ធកម្មទេ ប៉ុន្តែអាចអនុវត្តបានក្នុង ស្ថានភាពចាំបាច់ជាក់ស្តែងដែលមិនអាចអនុវត្តវិធីសាស្ត្រផ្សេងទៀតបាន និងដោយមាន ការអនុញ្ញាតយល់ព្រមជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យភាពជាក់ស្តែង ដើម្បីអនុវត្តឲ្យបានរលូននូវគោលការណ៍លទ្ធកម្មសាធារណៈ ។

### ៣.១.៨. ការទូទាត់ការចំណាយប្រាក់បុរេប្រទាន

ប្រាក់បុរេប្រទាន គឺជាការបើកផ្តល់ចំណាយមុនក្នុងករណីមានការចាំបាច់ ឬបន្ទាន់។ ជារៀងរាល់ឆ្នាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងបានចេញប្រកាសណែនាំដល់គ្រប់ក្រសួង ស្ថាប័នឲ្យរួសរាន់ប្រមូលឯកសារ ដើម្បីស្នើសុំទូទាត់ប្រាក់បុរេប្រទានដែលបានចំណាយ រួចហើយឲ្យបានមុនដំណាច់ឆ្នាំ ដោយគិតរួមទាំងចំណាយប្រាក់បុរេប្រទានជាវរូបិយប័ណ្ណ អន្តរជាតិដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ឲ្យតាមរយៈមូលប្បទានប័ត្រផងដែរ។ ប៉ុន្តែជាក់ស្តែង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងការទូទាត់ប្រាក់បុរេប្រទានពីមួយ ឆ្នាំទៅមួយឆ្នាំមិនត្រូវបានប្រព្រឹត្តឡើងទាន់ពេលវេលា និងទៀងទាត់ឡើយ។ ក្រសួង-ស្ថាប័ន អង្គភាពសាមីមួយចំនួន ក្រោយពីទទួលបានការបើកផ្តល់ និងធ្វើការចំណាយរួចហើយពុំសូវ បានយកចិត្តទុកដាក់រួសរាន់ប្រមូលឯកសារដើម្បីស្នើសុំធ្វើការទូទាត់ជំរះឲ្យបានត្រឹមត្រូវ និង ទាន់ពេលវេលាកំណត់នោះទេ។ ជាអាទិ៍ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ ប្រាក់បុរេប្រទាន ដែលបានប្រតិបត្តិចំណាយរួចហើយ តែពុំទាន់មានឯកសារទូទាត់ជំរះ មានចំនួន១៣១.០៥៩ លានរៀល។

អាស្រ័យដូចនេះ ដើម្បីគ្រប់គ្រងការចំណាយថវិកាបុរេប្រទានឲ្យបានល្អ និងសម្រួល ដល់ការទូទាត់ជំរះបញ្ជីឲ្យបានស្របតាមឆ្នាំថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមាន វិធានការច្បាស់លាស់ ចំពោះក្រសួង-ស្ថាប័នដែលមានភាពយឺតយ៉ាវក្នុងការប្រមូលឯកសារ ទូទាត់ និងគ្មានឯកសារទូទាត់ សំដៅអនុវត្តឲ្យស្របតាមការណែនាំខាងលើ ។

ឆ្លើយតបនឹងការលើកនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងមានការលំបាក ព្រោះខ្ទង់ចំណាយខ្លះមានលក្ខណៈបន្ទាន់ ដែលពុំមានការគ្រោងទុក ហើយតម្រូវឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុញ្ញាតឲ្យសាមីក្រសួង-ស្ថាប័ន ធ្វើបុរេប្រទានសាច់ប្រាក់ពីអគ្គនាយកដ្ឋានរតនាគារជាតិ។ ចំណែកការបុរេប្រទានផ្នែកវិនិយោគ គឺជានីតិវិធីដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុញ្ញាត ពីព្រោះថា ខ្ទង់ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនអាចអនុញ្ញាតឲ្យសាមីក្រសួង-អង្គភាពធ្វើអាណត្តិបើកប្រាក់ចំណាយផ្ទាល់ ដោយពុំទាន់មានលិខិតយុត្តិការចំណាយបានទេ ហើយនៅពេលសំណង់ចប់រួចរាល់ មានលិខិតយុត្តិការចំណាយគ្រប់គ្រាន់ត្រឹមត្រូវ ទើបអនុញ្ញាតឲ្យសាមីក្រសួង-អង្គភាពធ្វើអាណត្តិនិយ័តកម្មទូទាត់។ ប៉ុន្តែទោះបីជាការបុរេប្រទានមានលក្ខណៈដូចម្តេចក្តី ក៏ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមើលឃើញថា ក្រសួង-ស្ថាប័ន អង្គភាពសាមីចំណាយមួយចំនួនពុំសូវបានយកចិត្តទុកដាក់ធ្វើការទូទាត់ប្រាក់បុរេប្រទាន ដែលខ្លួនបានយកទៅចំណាយរួចហើយនោះទេ សូម្បីតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្លាប់មានវិធានការតឹងរឹងមួយចំនួនរួចហើយក៏ដោយ ព្រោះក្រសួង-ស្ថាប័នមួយចំនួន មានគំនិតកេងតណាទានទុកចំណាយលើមុខសញ្ញាផ្សេងទៅវិញ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមបញ្ជាក់បន្ថែមថា ករណីខ្លះបានកើតឡើងជាយូរឆ្នាំមកហើយ ហើយត្រូវបានពិនិត្យឃើញថា នៅមានភាពយឺតយ៉ាវក្នុងការទូទាត់ជំរះបញ្ជីនៅឡើយ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរមានវិធានការឲ្យបានកាន់តែប្រសើរ ។

### ៣.១.៩. ការគ្រប់គ្រងការប្រើប្រាស់អាជ្ញាប័ណ្ណសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសោតទស្សន៍

តាមគោលការណ៍ណែនាំរបស់ក្រសួងព័ត៌មាន ស្តីពីការគ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍នៅកម្ពុជា គ្រប់ស្ថានីយ៍វិទ្យុ ទូរទស្សន៍ អង្គភាពសារព័ត៌មាន ព្រឹត្តប័ត្រទស្សនាវដ្តីជាតិ និងអន្តរជាតិ ដែលទទួលបានអាជ្ញាប័ណ្ណមានកំណត់ និងមិនកំណត់ សុពលភាពពីក្រសួងព័ត៌មាន ត្រូវមកសុំបន្តសុពលភាពសារជាថ្មីក្នុងចន្លោះពី២ទៅ៣ឆ្នាំម្តង។ ប៉ុន្តែតាមការពិនិត្យស្ថិតិស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងអង្គភាពសារព័ត៌នានា គិតត្រឹមថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៨ សរុបមានចំនួន៦៦៥អាជ្ញាប័ណ្ណ ក្នុងនោះអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានអាជ្ញាប័ណ្ណស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងអង្គភាពសារព័ត៌មាន ហួសសុពលភាពចំនួន២០៨អាជ្ញាប័ណ្ណ និងអាជ្ញាប័ណ្ណមិនកំណត់សុពលភាពចំនួន៥៤អាជ្ញាប័ណ្ណ ពុំបានមកសុំបន្តសុពលភាពសារជាថ្មីតាមការណែនាំខាងលើឡើយ ។

អាស្រ័យហេតុនេះ ដើម្បីគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឲ្យមានប្រសិទ្ធភាព ក្រសួងព័ត៌មានត្រូវណែនាំអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ធ្វើការត្រួតពិនិត្យលើការចេញ និងការប្រើប្រាស់អាជ្ញាប័ណ្ណផ្សព្វផ្សាយព័ត៌មានឲ្យបានហ្មត់ចត់ និងទាន់ពេលវេលា ។

ចំពោះករណីនេះ ក្រសួងព័ត៌មានបានបំភ្លឺថា ដើម្បីពង្រឹងការងារគ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ដ៏សំបូរបែប ក្នុងដំណាក់កាលថ្មីនៃការវិវត្តន៍រីកចម្រើនដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ រាជរដ្ឋាភិបាលបានបង្កើតអគ្គនាយកដ្ឋានថ្មីមួយបន្ថែមទៀត ចំណុះក្រសួងព័ត៌មាន តាមរយៈអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា

ឆ្នាំ២០០៧ គឺអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍។ ចំពោះមុខក្រសួងព័ត៌មាន កំពុងជំរុញឲ្យអគ្គនាយកដ្ឋាននេះរៀបចំនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តិចាំបាច់ និងធ្វើប្រតិបត្តិការយ៉ាងសកម្មក្នុងតួនាទីភារកិច្ច ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ក្នុងនោះក៏មានចំណុចមួយចំនួនដែលបានកត់សម្គាល់ក្នុងរបាយការណ៍សវនកម្មក្នុងការិយបរិច្ឆេទ២០០៧ ផងដែរ។ លទ្ធផលការងារទាំងនោះ កំពុងត្រូវបានរៀបរយជាបណ្តើរៗ ហើយនឹងឈានដល់រៀបរយដោយរលូនស្របតាមផែនការសកម្មភាព០៥ឆ្នាំ របស់ក្រសួងព័ត៌មាន ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ការងារនេះនឹងស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យយ៉ាងជិតដល់របស់ក្រសួងព័ត៌មាន ។

### ៣.១.១០. ការរក្សាទុកសាច់ប្រាក់ក្នុងបេឡា

ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីការរក្សាទុកសាច់ប្រាក់ក្នុងបេឡា បានកំណត់ចំពោះភ្នាក់ងារ ឬអង្គភាពប្រតិបត្តិចំណូលរបស់រដ្ឋ អាចរក្សាទុកសាច់ប្រាក់ក្នុងបេឡារបស់ខ្លួនត្រឹមចំនួន២លានរៀល ដល់ ៥លានរៀលប៉ុណ្ណោះ។ ប៉ុន្តែតាមការធ្វើសវនកម្មលើក្រសួង-ស្ថាប័នមួយចំនួនក្នុងការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានការរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់ ជាអាទិ៍ ៖

- ក្រសួងពាណិជ្ជកម្មមានចំនួនជាង១.០៥៦លានរៀល និង១៧៩.៤៥៥ដុល្លារអាមេរិក ។
- ក្រសួងសាធារណការ និងដឹកជញ្ជូន មានចំនួនជាង១៨៥លានរៀល និង ៣៩.៦១១ដុល្លារអាមេរិក ។

អាស្រ័យហេតុនេះ ដើម្បីឲ្យការគ្រប់គ្រងបេឡាសាច់ប្រាក់មានភាពកាន់តែល្អប្រសើរ ក្រសួងទាំងពីរ ព្រមទាំងក្រសួង-ស្ថាប័ននានាដែលមានចំណូល ត្រូវបង់ចំណូលចូលថវិកាឲ្យបានគ្រប់ចំនួន និងទាន់ពេលវេលា ស្របតាមប្រកាសខាងលើ ។

ចំពោះករណីនេះ ក្រសួងពាណិជ្ជកម្ម ក៏ដូចជាក្រសួងសាធារណការ និងដឹកជញ្ជូន បានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ និងរួសរាន់ពិនិត្យករណីនេះឡើងវិញ ។

ផ្អែកលើការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងទាំងពីរ ព្រមទាំងក្រសួង-ស្ថាប័ននានា នឹងធ្វើការបង់ចំណូលចូលថវិកាបានទាន់ពេលវេលា និងគ្រប់ចំនួន ។

## ៣.២. ការគ្រប់គ្រងថវិការាជធានី-ខេត្ត និងឃុំ-សង្កាត់

### ៣.២.១. ការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ (ដីធ្លី-ផ្ទះសំបែង)

តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ពន្ធប្រថាប់ត្រាត្រូវបង់ដោយអ្នកទទួលកម្មសិទ្ធិកាន់កាប់អចលនទ្រព្យ គិតជាសមាមាត្រលើតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិ និងសិទ្ធិកាន់កាប់ ព្រមទាំងហាមដល់ភ្នាក់ងារអាជ្ញាធរមានសមត្ថកិច្ចផ្តល់វិញ្ញាបនប័ត្រថ្មីសម្គាល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ បើម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ថ្មីនោះមិនបានបង់ពន្ធប្រថាប់ត្រា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់តម្លៃសម្រាប់រយៈកាល

នីមួយៗ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការគិតគូរប្រាក់ពន្ធដែលត្រូវបង់។ ទន្ទឹមនឹងនោះ នៅឆ្នាំ១៩៩៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការកំណត់តម្លៃពន្ធប្រថាប់ត្រា បានកំណត់តម្លៃសម្រាប់គិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ ក្រោមរូបភាពជាការលក់ ការដោះដូរ ការទទួលអំណោយ តាមតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិ និងសិទ្ធិកាន់កាប់។ ប៉ុន្តែតាមការធ្វើសវនកម្មនៅសាខាពន្ធដាររាជធានីភ្នំពេញ សាខាពន្ធដារខេត្តព្រះសីហនុ ស្ទឹងត្រែង កំពង់ឆ្នាំង កំពង់ចាម និងខេត្តស្វាយរៀងសម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញពុំមានការកំណត់តម្លៃអចលនទ្រព្យសម្រាប់រយៈកាលនីមួយៗតាមតម្លៃទីផ្សារទេ។ ជាក់ស្តែង ការកំណត់តម្លៃអចលនទ្រព្យអំពីដីធ្លី-ផ្ទះសម្បែង រវាងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ និងសាខាពន្ធដាររាជធានីភ្នំពេញ មានមូលដ្ឋានតម្លៃដោយឡែកពីគ្នា។ ម្យ៉ាងវិញទៀត សមត្ថកិច្ចតាមមូលដ្ឋាន ដូចជា ឃុំ-សង្កាត់ ខណ្ឌ-ស្រុក មួយចំនួនបានបញ្ជាក់សិទ្ធិកាន់កាប់លើលិខិតទិញ-លក់ដល់ម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ថ្មីនោះ ដោយពុំទាន់បានណែនាំឲ្យអ្នកទទួលសិទ្ធិកាន់កាប់អចលនវត្ថុមកបំពេញកាតព្វកិច្ចបង់ពន្ធប្រថាប់ត្រាឡើយ ។

អាស្រ័យហេតុនេះ ដើម្បីប្រមូលចំណូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលន-ទ្រព្យ តាមរយៈការទិញ-លក់ដីធ្លី ផ្ទះសំបែងឲ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីកំណត់តម្លៃមូលដ្ឋានគិតពន្ធលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ (ដីធ្លី-ផ្ទះសំបែង) សម្រាប់រយៈកាលនីមួយៗឲ្យបានច្បាស់លាស់ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺថា បទប្បញ្ញត្តិនៃច្បាប់ បានកំណត់អំពីការប្រមូលពន្ធប្រថាប់ត្រា ត្រូវគិតតាមតម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិនាថ្ងៃផ្ទេរកម្មសិទ្ធិ និងសិទ្ធិកាន់កាប់ ប៉ុន្តែបានផ្តល់សិទ្ធិឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់តម្លៃសម្រាប់រយៈកាលនីមួយៗ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាដែលត្រូវបង់។ ចំណូលពន្ធប្រថាប់ត្រា នាឆ្នាំកន្លងមកទទួលបានលទ្ធផលល្អប្រសើរ អាស្រ័យដោយមានការខិតខំបង្កើនការគ្រប់គ្រង និងកិច្ចសហការរវាងរដ្ឋបាលសារពើពន្ធ អាជ្ញាធរ-ដែនដី និងស្ថាប័នពាក់ព័ន្ធទប់ស្កាត់ការទិញ-លក់ស្ងាត់ស្ងៀម ដើម្បីបង្កើនការអនុវត្តន៍តាមនីតិវិធីត្រឹមត្រូវ និងម្យ៉ាងទៀតអាស្រ័យដោយយកតម្លៃទិញ-លក់ទីផ្សារធ្វើជាមូលដ្ឋាន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាពតាមរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិ និងទទួលយកអនុសាសន៍មកពិនិត្យពិចារណា ដើម្បីធ្វើការកំណត់មូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាសម្រាប់រយៈកាលនីមួយៗ ដោយកំណត់តម្លៃឲ្យសមស្របតាមការ ប្រែប្រួលថ្លៃទៅតាមតំបន់នីមួយៗ សំដៅកាត់បន្ថយឲ្យបានជាអតិបរមានូវបាតុភាពអសកម្ម ជាយថាហេតុ ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការតាមដានការអនុវត្តន៍ករណីនេះជាបន្តទៀត ។

### ៣.២.២. ការលើកលែងពន្ធបន្ថែម និងការប្រាក់លើដីធ្លីមិនបានប្រើប្រាស់

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៤ បានបញ្ជាក់ថា ភាពយឺតយ៉ាវមិនបានបង់ពន្ធអាករនឹងអាចអនុគ្រោះ ពន្យារពេលបង់ពន្ធអាករ បន្ថយពន្ធអាករ ឬអាចរួចពន្ធអាករបាន តែក្នុងករណីមានមហន្តរាយដល់សកម្មភាពអាជីវកម្ម ឬទ្រព្យសម្បត្តិអ្នកជាប់ពន្ធអាករ ឬអាយុជីវិតរបស់អ្នកជាប់ពន្ធអាករ ហើយករណីចុងក្រោយ រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអ្នកសម្រេច។ ប៉ុន្តែកន្លងមក ការងារដែលពាក់ព័ន្ធនឹងករណីនេះ មួយចំនួនពុំទាន់បានអនុវត្តស្របតាមច្បាប់ដែលកំណត់នោះទេ ដូចជា នៅសាខាពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្តព្រះសីហនុ សម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានការលើកលែងពន្ធបន្ថែម និងការប្រាក់ដីធ្លីមិនបានប្រើប្រាស់មួយចំនួនពីសំណាក់គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

អាស្រ័យហេតុនេះ ដើម្បីគ្រប់គ្រងការប្រមូលពន្ធឲ្យបានល្អប្រសើរ និងអនុវត្តឲ្យស្របតាមច្បាប់កំណត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអនុវត្តការលើកលែងពន្ធបន្ថែម និងការប្រាក់លើដីធ្លីមិនបានប្រើប្រាស់ឲ្យបានច្បាស់លាស់ថែមទៀត ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបញ្ជាក់ថា ក្រសួងបានចេញសារាចរណែនាំលេខ ០០២ សហវ.ពដ. ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាទាក់ទិននឹងពន្ធលើដីមិនបានប្រើប្រាស់ ដោយតម្រូវឲ្យមានការពិនិត្យ និងផ្តល់មតិតាមឋានានុក្រមពីសាខាពន្ធដារខេត្តមកអគ្គនាយកដ្ឋានពន្ធដារ ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងសម្រេចជាក្រោយ ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការតាមដានការអនុវត្តន៍ករណីនេះជាបន្តទៀត ។

**៣.២.៣. ការគ្រប់គ្រងចំណូលសម្រាប់ទម្រង់ការរដ្ឋបាល និងការអនុញ្ញាតរដ្ឋបាល**

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង បានតម្រូវឲ្យខេត្ត-ក្រុង កៀរគរប្រមូលចំណូលមិនមែនសារពើពន្ធសម្រាប់ជាគុណប្រយោជន៍របស់ខេត្ត-ក្រុង អំពីចំណូលពីការប្រើប្រាស់អំណាចរដ្ឋបាលរបស់ខ្លួន ដែលមានជាអាទិ៍ ចំណូលសម្រាប់ទម្រង់ការរដ្ឋបាល និងការអនុញ្ញាតរដ្ឋបាល។ អភិបាលខេត្ត-ក្រុងមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញដីកា និងលិខិតបទដ្ឋាននានា ដើម្បីកៀរគរប្រមូលចំណូលទាំងនោះ។ ជាក់ស្តែង តាមការធ្វើសវនកម្មនៅសាលាខេត្តព្រះសីហនុ ស្ទឹងត្រែង ពោធិ៍សាត់ កំពង់ឆ្នាំង ឧត្តរមានជ័យ កំពង់ស្ពឺ និងខេត្តប៉ៃលិន សម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាលាខេត្តទាំងនេះបានធ្វើការបញ្ជាក់លើលិខិតបទដ្ឋានសរុបចំនួន៥.៩៥៣ករណី និងបានចេញលិខិតអនុញ្ញាតរដ្ឋបាលចំនួន២.៤៨២ករណី ដោយមិនបានប្រមូលចំណូលពីការបញ្ជាក់លើលិខិតបទដ្ឋាន និងលិខិតអនុញ្ញាតរដ្ឋបាលទាំងនោះ បង់ចូលថវិកាខេត្តឡើយ ។

អាស្រ័យហេតុនេះ ដើម្បីកៀរគរប្រមូលចំណូលពីការប្រើអំណាចរដ្ឋបាលឲ្យមានប្រសិទ្ធភាពខ្ពស់ ខេត្ត និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរពិចារណារកវិធានការ ប្រមូល

ចំណូលសម្រាប់ទម្រង់ការរដ្ឋបាល និងការអនុញ្ញាតរដ្ឋបាលបង់ចូលថវិកាខេត្តឲ្យសមស្រប តាមច្បាប់ខាងលើ ។

ឆ្លើយតបចំពោះការលើកឡើងនេះ សាលាខេត្តមួយចំនួនបានបំភ្លឺថា សាលាខេត្ត ឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ និងសន្យាជំរុញការងារនេះឲ្យ ដំណើរការបានល្អ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា គ្រប់អង្គភាពពាក់ព័ន្ធនឹងធ្វើ កិច្ចសហការជំរុញឲ្យការប្រមូលចំណូលសម្រាប់ទម្រង់ការរដ្ឋបាល និងការអនុញ្ញាតរដ្ឋបាល ប្រព្រឹត្តទៅបានល្អ និងស្របតាមច្បាប់កំណត់ ។

### ៣.២.៤. ការប្រមូលចំណូល និងការកត់ត្រាចំណូលរបស់ឃុំ-សង្កាត់

អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការកំណត់ថ្លៃ ជាវក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រើសារពើពន្ធ បានបញ្ជាក់ថា ឃុំមានសិទ្ធិប្រមូល ចំណូលពីការលក់ក្រដាសអត្រានុកូលដ្ឋានឲ្យប្រជាជន។ អនុក្រឹត្យលេខ១៦ អនក្រ.បក ចុះ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ-សង្កាត់ បានកំណត់ថា ដើម្បីទទួលបានមូលនិធិ ក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបញ្ជាក់ថា បានប្រមូលទុនចូលរួមរបស់មូលដ្ឋាន ព្រមទាំងធនធាន ដទៃទៀត ដើម្បីបំពេញបន្ថែមលើការផ្ទេរមូលនិធិនៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។ ទន្ទឹមនឹង នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសណែនាំលេខ ៩៣៨ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ-សង្កាត់ បានតម្រូវឲ្យឃុំ-សង្កាត់កត់ត្រា ចំណូលក្នុង សៀវភៅបេឡាប្រតិបត្តិការផ្សេងៗ។ ប៉ុន្តែតាមការធ្វើសវនកម្មនៅតាមឃុំ-សង្កាត់ នៃខេត្តកោះកុង ពោធិ៍សាត់ បាត់ដំបង និងខេត្តព្រះសីហនុ សម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានឃុំមួយចំនួនបានប្រមូលចំណូលពីការលក់ ក្រដាសអត្រានុកូលដ្ឋាន និងចំណូលពីការរួមចំណែករបស់ប្រជាជន ដោយពុំបានចេញ បង្កាន់ដៃទទួលប្រាក់ និងពុំបានកត់ត្រាចំណូលទាំងនោះចូលក្នុងសៀវភៅបេឡាប្រតិបត្តិការ ផ្សេងៗនោះទេ ។

អាស្រ័យហេតុនេះ ដើម្បីឲ្យកិច្ចបញ្ជីកាគណនេយ្យមានតម្លាភាព និងមានជំនឿ ទុកចិត្ត មេឃុំ ចៅសង្កាត់ទាំងអស់ចាំបាច់ត្រូវអនុវត្តឲ្យស្របតាមគោលការណ៍គណនេយ្យ ខាងលើ ។

ចំពោះការលើកឡើងនេះ ក្រុមប្រឹក្សា និងគណនេយ្យករឃុំបានឯកភាពតាមការ លើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ហើយសន្យាថា នឹងខិតខំកែលំអរាល់ចំណុចខ្វះខាត ឲ្យបានល្អប្រសើរនាពេលខាងមុខ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រុមប្រឹក្សា និងគណនេយ្យករ ឃុំ នឹងធ្វើការអនុវត្តកែលំអឲ្យបានកាន់តែល្អប្រសើរ ។

### ៣.២.៥. ការបំបែកគម្រោងលទ្ធកម្មតម្រូវតាមសិទ្ធិសម្រេចរបស់ខេត្ត

ប្រកាសលេខ ០៩៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការអនុវត្តន៍វិសហមជ្ឈការកិច្ចលទ្ធកម្មសាធារណៈបានកំណត់ថា ខេត្ត-ក្រុង មានសិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈ ក្នុងកម្រិតទឹកប្រាក់ក្រោម៣០០លានរៀល។ ទន្ទឹមនឹងនេះ ខេត្តនីមួយៗមិនត្រូវបំបែកគម្រោងចំណាយ ដើម្បីតម្រូវតាមសិទ្ធិសម្រេចទទួលខុសត្រូវរបស់ខេត្តឡើយ។ ប៉ុន្តែតាមការធ្វើសវនកម្មនៅសាលាខេត្តពោធិ៍សាត់ ឧត្តរមានជ័យ កំពង់ស្ពឺ និងខេត្តប៉ៃលិន សម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាលាខេត្តបានបំបែកគម្រោងលទ្ធកម្មធំៗ ចំនួន ០៦ ទៅជាគម្រោងតូចៗចំនួន៣០គម្រោង ដើម្បីតម្រូវតាមសិទ្ធិសម្រេចរបស់ខេត្ត មានដូចខាងក្រោម ៖

- ការធ្វើរបាំងទប់ដីច្រាំងស្ទឹងពោធិ៍សាត់ មានទឹកប្រាក់ជាង៥០០លានរៀល ត្រូវបានបំបែកជា០២គម្រោង
- ការជួសជុលសណ្ឋាគារ និងសាលប្រជុំសាលាខេត្តពោធិ៍សាត់ មានទឹកប្រាក់ជាង៣០០លានរៀល ត្រូវបានបំបែកជា០២គម្រោង
- ការជួសជុលផ្លូវក្រាលក្រួសក្រហមតំបន់រដ្ឋបាលខេត្តឧត្តរមានជ័យ មានទឹកប្រាក់ជាង៩០០លានរៀល ត្រូវបានបំបែកជា០៤គម្រោង និងការសាងសង់អាគារសាលាខេត្តថ្មី មានទឹកប្រាក់ជាង៣.០០០លានរៀល ត្រូវបានបំបែកជា១៨គម្រោង
- ការស្ថាបនាផ្លូវ MACADAM និងដាក់លូក្នុងខេត្តប៉ៃលិន មានទឹកប្រាក់ជាង៩០០លានរៀល ត្រូវបានបំបែកជា០៤គម្រោង
- ការជួសជុលផ្លូវក្រាលក្រួសក្រហមក្នុងខេត្តកំពង់ស្ពឺ មានទឹកប្រាក់៩០០លានរៀល ត្រូវបានបំបែកជា០៤គម្រោង ។

អាស្រ័យហេតុនេះ ដើម្បីធានាបាននូវកិច្ចលទ្ធកម្មមានលក្ខណៈសមស្រប សាលាខេត្តត្រូវអនុវត្តឲ្យបានពេញលេញតាមប្រកាសខាងលើ ។

ឆ្លើយតបចំពោះការលើកឡើងនេះ សាលាខេត្តបានបំភ្លឺថា សាលាខេត្តសូមឯកភាព និងសន្យាថា នឹងធ្វើការកែលំអរាល់ចំណុចខ្វះខាតឲ្យបានប្រសើរ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា សាលាខេត្តនឹងធ្វើការអនុវត្តន៍កែលំអឲ្យបានកាន់តែល្អប្រសើរថែមទៀត ។

## ៣.៣. ការអនុវត្តន៍គម្រោងវិនិយោគ

### ការវាយតម្លៃ និងការពន្យារសុពលភាពលើសំណើដេញថ្លៃ

ផ្អែកតាមគោលការណ៍ណែនាំលទ្ធកម្មក្រោមគម្រោងឥណទានធនាគារពិភពលោក ម្ចាស់គម្រោងត្រូវបញ្ចប់ការវាយតម្លៃលើសំណើដេញថ្លៃ និងផ្តល់កិច្ចសន្យានៅក្នុងអំឡុងពេលសុពលភាពដំបូងចំនួន១៨០ថ្ងៃ។ ក្នុងករណីមានការពន្យារសុពលភាពសំណើដេញថ្លៃ ម្ចាស់គម្រោងត្រូវធ្វើលិខិតជូនដំណឹងស្តីពីការពន្យារសុពលភាព ឲ្យបានមុនកាលបរិច្ឆេទផុតកំណត់។ ចំពោះថ្លៃស្នើឡើងដោយអ្នកដេញថ្លៃ ត្រូវអនុវត្តការគណនាតាមលក្ខខណ្ឌឯកសារដេញថ្លៃ។ ចំណែកអ្នកដេញថ្លៃ មិនត្រូវបានអនុញ្ញាតឲ្យស្នើសុំធ្វើការផ្លាស់លក្ខខណ្ឌ

ផ្សេងៗនៃសំណើដេញថ្លៃឡើយ។ ប៉ុន្តែតាមការធ្វើសវនកម្មនៅអគ្គិសនីកម្ពុជាសម្រាប់ការិយបរិច្ឆេទ២០០៧ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានកិច្ចសន្យាចំនួន០៥ ដែលការអនុវត្តន៍វាយតម្លៃលើសំណើដេញថ្លៃមានរយៈពេលលើសសុពលភាពចន្លោះពី៣៥ ដល់៥០៧ថ្ងៃ។ ក្នុងនោះដែរ មានកិច្ចសន្យាមួយដែលក្រុមហ៊ុនទទួលបានជ័យលាភីនៃការដេញថ្លៃបានបដិសេធការចុះកិច្ចសន្យា ហើយអគ្គិសនីកម្ពុជាពុំបានរឹបអូសប្រាក់កក់ធានាការដេញថ្លៃចំនួន២% ស្មើនឹងទឹកប្រាក់ចំនួន១០.០០០ដុល្លារអាមេរិក។ ចំណែកកិច្ចសន្យាមួយផ្សេងទៀត ក្រុមហ៊ុនដែលទទួលបានជ័យលាភីនៃការដេញថ្លៃ បានទទួលទឹកប្រាក់កិច្ចសន្យាលើសពីសំណើដេញថ្លៃចំនួន៣១៥.០០០ដុល្លារអាមេរិក ។

អាស្រ័យហេតុនេះ ដើម្បីឲ្យការអនុវត្តន៍គម្រោងបានត្រឹមត្រូវ ជៀសវាងនូវការអូសបន្លាយពេលវេលា និងខាតបង់ថវិកា អគ្គិសនីកម្ពុជាត្រូវអនុវត្តឲ្យស្របតាមកិច្ចសន្យា និងគោលការណ៍ណែនាំលទ្ធកម្មក្រោមគម្រោងឥណទានធនាគារពិភពលោក ។

ឆ្លើយតបទៅនឹងការលើកឡើងខាងលើ អគ្គិសនីកម្ពុជាបានបំភ្លឺថា អគ្គិសនីកម្ពុជាបានអនុវត្តតួនាទីរបស់ខ្លួនដោយគោរពនីតិវិធីលទ្ធកម្មដែលបានកំណត់ទាំងស្រុង ប៉ុន្តែមូលហេតុចម្បងនៃការយឺតយ៉ាវទាំងនេះ គឺលើសពីសមត្ថភាពគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា។ រាល់ការងារវាយតម្លៃ ឬការអនុម័តនានាទាក់ទងនឹងឯកសារដេញថ្លៃ ក៏ដូចជាការកែប្រែនានាក្នុងកិច្ចសន្យា អគ្គិសនីកម្ពុជាពុំអាចធ្វើការសម្រេចឡើងដោយឯកតោភាគីឡើយ ពោលគឺការងារទាំងនេះត្រូវបានអនុវត្តដោយអគ្គិសនីកម្ពុជា ដែលមានកិច្ចសហការពីទីប្រឹក្សាអនុវត្តគម្រោង និងទាមទារឲ្យមានការចូលរួមឯកភាពពីគណៈកម្មការវាយតម្លៃត្រួតពិនិត្យលទ្ធកម្មគម្រោង ដែលមានសមាសភាពមកពីអន្តរក្រសួង និងភាគីធនាគារពិភពលោកដែលជាអ្នកផ្តល់ឥណទាន។ម្យ៉ាងវិញទៀត គម្រោងមួយចំនួនដូចជា កិច្ចសន្យាលេខ WB-EDC-03 ការងារសាងសង់មជ្ឈមណ្ឌលជាតិ បញ្ជាមានលក្ខណៈពិសេសដោយត្រូវប្រើប្រាស់បច្ចេកវិទ្យាថ្មី ដែលប្រទេសកម្ពុជាពុំទាន់មានកន្លងមក ក្នុងនោះតម្រូវឲ្យមានការពិនិត្យយ៉ាងហ្មត់ចត់ពីសំណាក់ទីប្រឹក្សាបច្ចេកទេសគម្រោងក្នុងការជ្រើសរើសយកគំរូ (Model) ណាមួយ ដើម្បីចៀសវៀងបញ្ហាទៅថ្ងៃក្រោយ។ ជាក់ស្តែង នៅពេលធ្វើការវាយតម្លៃលើសំណើដេញថ្លៃកិច្ចសន្យាលេខ WB-EDC-05 និង WB-EDC-02 អគ្គិសនីកម្ពុជាបានចំណាយពេលវេលាជាច្រើនដើម្បីរង់ចាំការឆ្លើយតបពីភាគីធនាគារពិភពលោក។ ដោយហេតុថា ភាគីធនាគារពិភពលោកបានធ្វើការផ្លាស់ប្តូរមន្ត្រីទទួលគំរោងរបស់គេ ដែលអ្នកមកគ្រប់គ្រងថ្មីត្រូវការពេលវេលាមួយដើម្បីស្វែងយល់តាំងពីដើមរឿង និងម្យ៉ាងនៅពេលនោះ ភាគីធនាគារពិភពលោកបានកំពុងជួបប្រទះនូវភាពមិនប្រក្រតីនៃកិច្ចលទ្ធកម្ម (Missed Procurement) ចំនួន០៦គម្រោង ជាមួយស្ថាប័នផ្សេងទៀត ធ្វើឲ្យការពិនិត្យ និងឯកភាពលើរាល់ឯកសារលទ្ធកម្មនានា ត្រូវបានបង្កើនការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ ជាហេតុធ្វើឲ្យមានការចំណាយពេលវេលាកាន់តែច្រើនបន្ថែមពីលើនោះទៀត។ មូលហេតុទាំងនេះ បណ្តាលឲ្យមានការយឺតយ៉ាវក្នុងវាយតម្លៃសំណើដេញថ្លៃ និងបណ្តាលឲ្យមានការពន្យារសុពលភាពលើសំណើដេញថ្លៃជាច្រើនកញ្ចប់ និងមានកញ្ចប់ការងារមួយចំនួន តម្រូវធ្វើការកែប្រែតម្លៃ និងឈាន

ដល់ការលុបគម្រោងការចោលតែម្តង ។ ដើម្បីបង្កើនប្រសិទ្ធិភាពការងារគ្រប់គ្រងគម្រោងឲ្យកាន់តែមានប្រសិទ្ធិភាព អគ្គិសនី កម្ពុជាស្នើឲ្យមានការកាត់បន្ថយការិយាធិបតេយ្យដែលមានក្នុងនីតិវិធីលទ្ធកម្ម គម្រោងបច្ចុប្បន្ន ទាំងនីតិវិធីរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជានីតិវិធីរបស់ដៃគូអភិវឌ្ឍន៍នានា ។ ជាមួយគ្នានេះផងដែរ អគ្គិសនីកម្ពុជាបានប្តេជ្ញានឹងធ្វើការបង្កើនសមត្ថភាពធនធានមនុស្សឲ្យកាន់តែប្រសើរសម្រាប់ការងារគ្រប់គ្រងអនុវត្តគម្រោង ដើម្បីចៀសវាងបញ្ហាប្រឈមនានា ដែលអាចកើតមានឡើងក្នុងការងារអនុវត្តគម្រោងនៅថ្ងៃអនាគត ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមឲ្យអគ្គិសនីកម្ពុជាសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គភាពពាក់ព័ន្ធ ដើម្បីអនុវត្តគម្រោងឲ្យស្របតាមកិច្ចសន្យា ។

## ៤. ការតាមដានលើការអនុវត្តន៍កែលំអតាមអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា រាល់ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មទាំងឡាយ ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើងជាបន្តបន្ទាប់ ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់បណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាមានមួយចំនួនបានកែលំអគួរជាទីមោទនៈ។ រីឯចំណុចមួយចំនួនទៀត នៅតែបន្តកើតមាន ជាអាទិ៍ ៖

ការត្រួតពិនិត្យទំនិញ ឬការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធនៅដើមទី នៅពុំទាន់បានប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនៅឡើយ។ តាមការធ្វើសវនកម្មកន្លងមកឃើញថា ទំនិញជាច្រើនបានហូរចូលមកក្នុងប្រទេស ឬបានធ្លាក់ដល់ដៃអ្នកប្រើប្រាស់រួចហើយ ទើបមានការបង្ក្រាប ឬចាប់ឲ្យបង់ពន្ធផ្សេងៗជាក្រោយ។ ករណីនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍កន្លងមកហើយ (ការិយបរិច្ឆេទ២០០៣ និង២០០៦)។ ដោយឡែកសម្រាប់ការិយបរិច្ឆេទ ២០០៧ ករណីបង្ក្រាបនៅចុងទីនេះមានចំនួន៦២៨ករណី ស្មើនឹង៤២% នៃផលបង្ក្រាបសរុប និងមានរថយន្ត ម៉ូតូជាច្រើនពាន់គ្រឿងទៀត ដែលម្ចាស់ទំនិញទាំងនោះស្ម័គ្រចិត្តចូលខ្លួនមកសុំបង់ពន្ធ បន្ទាប់ពីបាននាំចូលដល់ផ្ទៃក្នុងប្រទេស ឬបានប្រើប្រាស់រួចហើយ ។

វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញ គឺជាឯកសារសំខាន់មួយបញ្ជាក់អំពីថ្លៃ អត្តសញ្ញាណ និងគោលដៅនៃទំនិញ ហើយត្រូវបានក្រុមហ៊ុន អាជីវករ ឬ អ្នកដំណើរទាំងឡាយប្រើប្រាស់ជាផ្លូវការសម្រាប់ការនាំចេញ-នាំចូលទំនិញគ្រប់ប្រភេទ។ ប៉ុន្តែ តាមការធ្វើសវនកម្មកន្លងមកឃើញថា វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញដែលបានយកមកប្រើប្រាស់ទាំងនោះ ភាគច្រើនត្រូវបានទទួលស្គាល់ថា ជាឯកសារដែលបង្កើតឡើងដោយក្រុមហ៊ុន ឬបុគ្គលនាំចូលខ្លួនឯង ដែលអាចជាឯកសារមួយពុំទាន់អាចបញ្ជាក់បាននូវភាពជាក់ស្តែងនៃថ្លៃទំនិញ។ ករណីនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍ជាច្រើនដងមកហើយ (ការិយបរិច្ឆេទ២០០២, ២០០៥ និង២០០៦) ដោយឡែកសម្រាប់ការិយបរិច្ឆេទ២០០៧នេះ នៅមានការប្រើប្រាស់ជាច្រើននៅឡើយ ។

កិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងការតាមដានសកម្មភាពអាជីវកម្មនាំចូលរបស់ក្រុមហ៊ុន-សហគ្រាស នៅតែពុំទាន់មានលក្ខណៈគ្រប់

ជ្រុងជ្រោយ ពោលនៅក្នុងឆ្នាំ២០០៧នេះ ក្រុមហ៊ុន-សហគ្រាសដែលគ្មានឈ្មោះក្នុងបញ្ជីចរន្តរបស់ពន្ធដារ តែបានធ្វើសកម្មភាពនាំទំនិញចូល មានចំនួន១៣៨ករណី។ ចំនួននេះ មានការកើនឡើង៩៦ករណី បើធ្វើការប្រៀបធៀបទៅនឹងឆ្នាំ២០០៦ ។

ការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាចប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានការរៀបចំឲ្យមានបញ្ជីតម្លៃមូលដ្ឋានគិតពន្ធ និងការបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ និងរាជធានី-ខេត្តនីមួយៗឲ្យបានច្បាស់លាស់។ ប៉ុន្តែតាមការធ្វើសវនកម្មកន្លងមកឃើញថា អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់តាមរាជធានី-ខេត្ត ពុំទាន់អនុវត្តឲ្យបានពេញលេញតាមតួនាទីរបស់ខ្លួននោះទេ។ ករណីនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍កន្លងមកហើយ ពិសេសនៅក្នុងរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០០៦។ ដោយឡែកសម្រាប់ការិយបរិច្ឆេទ២០០៧ តាមលទ្ធផលនៃការធ្វើតេស្តសវនកម្មឃើញថា ករណីមិនបានរៀបចំបញ្ជីតម្លៃមូលដ្ឋានគិតពន្ធ និងការមិនបានបង្កើតបញ្ជីដីត្រូវជាប់ពន្ធនេះ មានជាអាទិ៍ នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ កំពង់ចាម ស្វាយរៀង កោះកុង ស្ទឹងត្រែង ពោធិ៍សាត់ និងខេត្តប៉ៃលិន ។

ការចុះអាជីវកម្មដ្ឋានរបបម៉ៅការក្នុងបញ្ជីពន្ធ គឺជាមូលដ្ឋានចាំបាច់មួយក្នុងការប្រមូលពន្ធតាមរបបម៉ៅការ។ ការប្រមូលពន្ធតាមរបបម៉ៅការអាចធ្វើទៅបាន និងមានលក្ខណៈគ្រប់គ្រាន់លុះត្រាអាជីវកម្មដ្ឋានទាំងនោះត្រូវបានចុះក្នុងបញ្ជីពន្ធប្រចាំឆ្នាំ។ រដ្ឋបាលសារពើពន្ធ (អង្គភាពពន្ធដារ) មានតួនាទីជំរឿនអ្នកជាប់ពន្ធ កំណត់ពន្ធ និងដាក់បញ្ចូលអាជីវកម្មដ្ឋានទៅក្នុងបញ្ជីពន្ធ ប៉ុន្តែតាមការធ្វើសវនកម្មកន្លងមកឃើញថា មូលដ្ឋានអាជីវកម្មមួយចំនួនមិនត្រូវបានចុះបញ្ចូលក្នុងបញ្ជីពន្ធនោះទេ។ ដោយឡែកសម្រាប់ការិយបរិច្ឆេទ២០០៧នេះ គ្រាន់តែការធ្វើតេស្តលើមូលដ្ឋានអាជីវកម្មនៅទីតាំងមួយចំនួននៃខេត្តកោះកុង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តបាត់ដំបង គឺមានជិត២០០មូលដ្ឋានដែលមិនត្រូវបានបញ្ចូលក្នុងបញ្ជីពន្ធ ។

ការគ្រប់គ្រងប្រមូលចំណូលដីសម្បទានត្រូវអនុវត្តតាមលិខិតលេខ៨០៣សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីការកំណត់ថ្លៃឈ្នួលដីសម្បទាន ដែលផ្តល់តួនាទីឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកចុះទៅធ្វើការវាយតម្លៃ និងកំណត់ថ្លៃឈ្នួលដី។ ប៉ុន្តែចាប់តាំងពី ឆ្នាំ២០០០ រហូតដល់ឆ្នាំ២០០៧នេះ ក្រសួងទាំងពីរខាងលើពុំទាន់បានចុះធ្វើការវាយតម្លៃ និងកំណត់ថ្លៃឈ្នួលដីសម្បទានដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនវិនិយោគលើផ្ទៃដីសរុបជាងមួយលានហិកតានោះនៅឡើយ ។

ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបានកំណត់ឱសានវាទត្រឹមវេលាម៉ោងដប់ប្រាំពីរ និងសាមសិបនាទី នាថ្ងៃទី២៩ ខែធ្នូ នៃឆ្នាំសារពើពន្ធ។ ប៉ុន្តែ តាមការធ្វើសវនកម្មកន្លងមកឃើញថា ប្រការនេះតែងតែកើតមានក្រោយថ្ងៃឱសានវាទបិទបញ្ជីជានិច្ច ដែលបង្កឲ្យមានការកកស្ទះអាណត្តិបើកប្រាក់ និងលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំឲ្យបានទាន់

ពេលវេលា។ ករណីនេះអាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍កន្លងមកហើយ ប៉ុន្តែនៅក្នុងការិយបរិច្ឆេទ២០០៧ ករណីនេះនៅតែកើតមានដដែល ។

ការដកចំណូលមួយចំនួនយកទៅចំណាយមុនការបង់ចូលថវិការដ្ឋ គឺជាប្រការមួយមិនស្របនិងច្បាប់ និងលិខិតបទដ្ឋាននានាស្តីពីហិរញ្ញវត្ថុ ជាអាទ៍ចំណូលត្រូវកត់ត្រាចូលទាំងស្រុង មិនត្រូវទូទាត់ជាមួយចំណាយឡើយ។ ប៉ុន្តែផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មកន្លងមកឃើញថា អង្គភាព ប្រតិបត្តិចំណូលមួយចំនួនដូចជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងព័ត៌មាន និងក្រសួងពាណិជ្ជកម្ម រមែងតែងដកចំណូលយកទៅចំណាយជារង្វាន់ដើម្បីលើកទឹកចិត្តក្នុង ការប្រមូលចំណូល និងចំណាយផ្សេងៗ មុនការបង់ចូលថវិការដ្ឋ និងពុំមានការកត់ត្រាចូលក្នុងថវិកានោះទេ។

ការកត់ត្រាតាមដានបំណុល គឺជាកាតព្វកិច្ចរបស់អគ្គនាយកដ្ឋានរតនាគារជាតិដែលមានតួនាទីជាគណនេយ្យករសាធារណៈ បើយោងតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ២០០៨ ។ ប៉ុន្តែតាមការធ្វើសវនកម្មកន្លងមក ក៏ដូចជា ការិយបរិច្ឆេទ២០០៧នេះឃើញថា រាល់បំណុលទាំងឡាយពុំទាន់មានការកត់ត្រាតាមដានប្រមូលផ្តុំឲ្យបានពេញលេញនៅអគ្គនាយកដ្ឋានរតនាគារជាតិនោះទេ ដែលនាំឲ្យមានការលំបាកក្នុងការតាមដាន និងត្រួតពិនិត្យ ។

## ៥. សេចក្តីសន្និដ្ឋាន

ឆ្លងតាមការចង្អុលបង្ហាញនូវចំណុចខ្វះខាតនានា និងការផ្តល់អនុសាសន៍កែលំអជាបន្តបន្ទាប់នាពេលកន្លងមក ក៏ដូចនៅពេលបច្ចុប្បន្ន អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងខិតខំអនុវត្តកែលំអនូវរាល់ចំណុចខ្វះខាតទាំងនោះឲ្យបានទាន់ពេលវេលា និងជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលនេះទៀតនៅពេលអនាគត ដែលទាំងនេះគឺជាការចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងអភិបាលកិច្ចលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឲ្យបានកាន់តែល្អប្រសើរ និងជាកំលាំងចលករមួយក្នុងការអភិវឌ្ឍន៍សង្គមជាតិយើង ។

ជាមួយគ្នានេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា សាធារណជនទាំងឡាយនឹងចូលរួមផ្តល់មតិស្ថាបនាលើលទ្ធផលសម្រេចបាននេះ ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួន សំដៅលើកកំពស់គុណភាពសវនកម្ម ដើម្បីចូលរួមចំណែកយ៉ាងសក្តិសមក្នុងការកសាង ការពារ និងអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយចីរភាព ៕